ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ះរដ្ឋាភិបាលកម្ពុជា
លេខ :៧៩ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការសុំទារកកំព្រា ឬ កុមារកំព្រាយកទៅចិញ្ចឹមជាកូននៅបរទេស

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញក្រឹត្យ លេខ ៥៦ ក្រ ចុះថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ ១៩៨៩ របស់ក្រុមប្រឹក្សារដ្ឋ នៃរដ្ឋកម្ពុជា ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសញ្ជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ.បក ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីតាមសម័យប្រជុំ ថ្ងៃទី ០២ ខែមីនា ឆ្នាំ២០០១ ។

## ស ម្រេ ច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះ កំណត់សមត្ថកិច្ច លក្ខខណ្ឌ និងនីតិវិធី នៃការសុំទារកកំព្រា ឬកុមារកំព្រា យកទៅចិញ្ចឹមជាកូន នៅក្រៅប្រទេស ។

## ជំពូកទី ២

## សមត្ថកិច្ច លក្ខខណ្ឌ និងនីតិវិធីនៃការសុំទារកកំព្រា ឬកុមារកំព្រាយកទៅចិញ្ចឹមនៅបរទេស

**មាត្រា ២.-**

ជនបរទេសជាសាមីអ្នកស្នើសុំទារកកំព្រា ឬកុមារកំព្រាយកទៅចិញ្ចឹមបីបាច់ជាកូននៅបរទេស ត្រូវបំពេញលក្ខខណ្ឌ និងនីតិវិធីដូចមានចែងក្នុងអនុក្រឹត្យនេះ។

**មាត្រា ៣.-**

សាមីអ្នកស្នើសុំជាប្តីប្រពន្ធត្រូវបានរៀបអាពាហ៍ពិពាហ៍ និងមានអាយុពី ២៥ ឆ្នាំ ដល់ ៥៥ ឆ្នាំ ។ ចំពោះអ្នកនៅលីវ អាចអនុញ្ញាតឱ្យសុំបានតែអ្នកនៅលីវដែលមានអាយុចាប់ពី ៤០ ឆ្នាំ ដល់ ៥០ ឆ្នាំ ។ ចំពោះសាមីអ្នកស្នើសុំមិនអាចសុំកូនយកទៅចិញ្ចឹមលើសពី ២ នាក់ បានឡើយ ។ ត្រូវបានអនុញ្ញាតឱ្យសុំកូនបាន លុះត្រាតែអ្នកស្នើសុំគ្មានកូន ឬមានកូនមិនលើសពី ២ នាក់ ។

**មាត្រា ៤.-**

សាមីអ្នកស្នើសុំត្រូវ[redacted] ការងារ បណ្ណុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា [redacted]ជាតិ ដោយមានភ្ជាប់ឯកសារ ដូចខាងក្រោម :

- ទំរង់ពាក្យសុំ
- លិខិតអនុញ្ញាតឱ្យសុំកូនចិញ្ចឹមពីអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសសាមីរបស់សាមីអ្នកស្នើសុំ
- របាយការណ៍ស្តីពីស្ថានភាពគ្រួសារ ដោយមានបញ្ជាក់ពីចំនួនសមាជិកគ្រួសារ ដែលធ្វើដោយភ្នាក់ងារមានជំនាញលើការងារនេះ ហើយមានការទទួលស្គាល់ពីក្រសួងមានសមត្ថកិច្ច នៃប្រទេសសាមី របស់សាមីអ្នកស្នើសុំ
- សេចក្តីចម្លងសំបុត្រ ឬវិញ្ញាបនប័ត្រកំណើតរបស់សាមីអ្នកស្នើសុំ
- សេចក្តីចម្លងលិខិតអាពាហ៍ពិពាហ៍ ឬលិខិតលែងលះគ្នា ឬលិខិតបញ្ជាក់ថានៅលីវ
- លិខិតបញ្ជាក់អំពីសុខភាពរបស់សាមីអ្នកស្នើសុំ
- របាយការណ៍ស្តីពីចិត្តវិទ្យាធ្វើឡើងដោយគ្រូពេទ្យចិត្តវិទ្យា ដែលទទួលស្គាល់ដោយរដ្ឋាភិបាលនៃប្រទេសសាមី របស់សាមីអ្នកស្នើសុំ
- លិខិតបញ្ជាក់ថាគ្មានទោស ចេញដោយអាជ្ញាធរក្នុងប្រទេសកំណើត ឬកន្លែងដែលសាមីអ្នកស្នើសុំបានរស់នៅ ឬ សំបុត្រថ្កោលទោសចេញដោយក្រសួងមានសមត្ថកិច្ច
- លិខិតបញ្ជាក់អំពីកិរិយាមារយាទ នៅក្នុងកន្លែងប្រកបការងារ និងនៅក្នុងសង្គមរស់នៅ ចេញដោយអាជ្ញាធរមានសមត្ថកិច្ច
- សេចក្តីបញ្ជាក់អំពីស្ថានភាពហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់សាមីអ្នកស្នើសុំ ចេញដោយអាជ្ញាធរមានសមត្ថកិច្ច
- គំរូនៃឧក្រិដ្ឋពាក្យសិទ្ធិជាកូន និងរស់នៅការសិក្សា ព្រមទាំងសិទ្ធិទទួលកេរ្តិ៍មរតក ដូចកូនបង្កើតរបស់ខ្លួន

- រូបថតរបស់សាមីអ្នកស្នើសុំ យកក្នុងកំឡុងពេលពីរខែចុងក្រោយ
- កិច្ចសន្យារបស់សាមីអ្នកស្នើសុំ ស្តីពីការផ្តល់ពត៌មានលើការចិញ្ចឹមកូន ចាប់ពីពេលដែលយកកូនចិញ្ចឹមចេញពីប្រទេសកម្ពុជាមួយឆ្នាំម្តង១ រហូតដល់អាយុ ១៨ ឆ្នាំ មកក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ហើយរបាយការណ៍នោះត្រូវបានត្រួតពិនិត្យ និងបញ្ជាក់ពីភាពត្រឹមត្រូវ ដោយក្រសួងមានសមត្ថកិច្ចខាងការងារសុំកូនចិញ្ចឹម នៃប្រទេសរបស់សាមីអ្នកស្នើសុំ ហើយចម្លងជូនទៅស្ថានទូតខ្មែរដែលប្រចាំនៅប្រទេសសាមីអ្នកស្នើសុំ
- សេចក្តីចំលងលិខិតឆ្លងដែនរបស់សាមីអ្នកស្នើសុំ
- លិខិតបញ្ជាក់ពីស្ថានទូតនៃប្រទេសរបស់សាមីអ្នកស្នើសុំ ចំពោះឯកសារទាំងអស់ខាងលើពីភាពត្រឹមត្រូវ ។

មាត្រា ៥ .-

ទារកកំព្រា ឬកុមារកំព្រាដែលត្រូវបានអនុញ្ញាតឱ្យសុំយកទៅចិញ្ចឹម ត្រូវមានលក្ខណៈវិនិច្ឆ័យ និងសំណុំលិខិតដូចខាងក្រោមៈ

ក- មានអាយុក្រោម ៨ ឆ្នាំ

ខ- រស់នៅក្រោមការថែទាំរបស់មជ្ឈមណ្ឌលកុមារកំព្រារដ្ឋ ឬមណ្ឌលឯទៀតដែលគ្រប់គ្រងដោយ ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

គ- រស់នៅក្នុងមណ្ឌលអស់រយៈពេល ៣ ខែ យ៉ាងតិចមុនពេលត្រូវបានស្នើសុំ

ឃ- ត្រូវមានសំបុត្រកំណើតដែលចេញឱ្យដោយមន្ត្រីអត្រានុកូលដ្ឋាន

ង- ត្រូវមានវិញ្ញាបនប័ត្របញ្ជាក់ពីសុខភាពកាយសម្បទា ដែលចេញដោយវេជ្ជបណ្ឌិតមានសមត្ថកិច្ច ធ្វើការក្នុងមន្ទីរពេទ្យរដ្ឋ ឬគ្លីនិកឯទៀតដែលរដ្ឋទទួលស្គាល់ ។

មាត្រា ៦.-

ការជ្រើសរើសកូនត្រូវធ្វើឡើងតាមបញ្ជីរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា បានរៀបចំ និងត្រូវបានការឯកភាពពីអ្នកសុំកូនយកទៅចិញ្ចឹម ។ អ្នកស្នើសុំមានសិទ្ធិទៅមើលទារកកំព្រា ឬកុមារកំព្រាក្នុងមណ្ឌល មុនពេលធ្វើការសំរេចចិត្តថា ទទួលយក ឬមិនទទួលយក ។

មាត្រា ៧.-

ឯកសារស្នើសុំកូនទាំងអស់ត្រូវផ្ញើមកក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ តាមរយៈស្ថានទូតនៃប្រទេសសាមីប្រចាំនៅកម្ពុជា ។ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ត្រូវពិនិត្យលើសំណុំឯកសារទាំងអស់ដែលមានចែងក្នុងមាត្រា ៣ និងមាត្រា ៤ នៃអនុក្រឹត្យនេះ ក្នុងរយៈពេល ១៥ ថ្ងៃ ។ ប្រសិនបើសំណុំលិខិតរបស់សាមីអ្នកស្នើសុំមិនគ្រប់គ្រាន់ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ មានភារកិច្ចបដិសេធ ឬបញ្ជូនសំណុំឯកសារទៅឱ្យសាមីអ្នកស្នើសុំ ដើម្បីបំពេញសំណុំឯកសារឱ្យបានត្រឹមត្រូវឡើងវិញ ។ ក្រោយពីបានពិនិត្យរួចហើយ ត្រូវធ្វើលិខិតបញ្ជាក់យោបល់របស់ក្រសួង អមជាមួយសំណុំឯកសារពាក់ព័ន្ធទាំងអស់ បញ្ជូនមកក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ។

មាត្រា ៨.-

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ត្រូវពិនិត្យលើលក្ខខណ្ឌ និងបែបបទនានា ដែលសាមីអ្នកស្នើសុំបានបំពេញដូចមានចែងក្នុងមាត្រា ៥ នៃអនុក្រឹត្យនេះ ក្នុងរយៈពេល ២ ខែ ។ ក្រោយពីបានពិនិត្យសព្វគ្រប់ហើយ ត្រូវធ្វើលិខិតបញ្ជាក់រព័ត៌មានរបស់ក្រសួង បញ្ជូនរួមជាមួយសំណុំលិខិតពាក់ព័ន្ធទាំងអស់ ទៅទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីសុំសេចក្តីសម្រេចពីរាជរដ្ឋាភិបាល ។

មាត្រា ៩.-

ទីស្តីការគណៈរដ្ឋមន្ត្រី ត្រូវពិនិត្យសំណុំលិខិត និងដាក់ជូនប្រមុខរាជរដ្ឋាភិបាលសម្រេចក្នុងរយៈពេល ១៥ ថ្ងៃ ហើយត្រូវបញ្ជូនលិខិតសម្រេច ទៅក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ដើម្បីធ្វើលិខិតបញ្ជាក់ស្តីពីការសុំកូនចិញ្ចឹម និងជូនពត៌មានទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដើម្បីអញ្ជើញសាមីអ្នកស្នើសុំមកកាន់ប្រទេសកម្ពុជា តាមរយៈស្ថានទូតនៃប្រទេសសាមីប្រចាំនៅកម្ពុជា ។ ការសម្រេចជាវិជ្ជមាន ឬអវិជ្ជមាន ជាឆន្ទានុសិទ្ធិរបស់រាជរដ្ឋាភិបាល ។

មាត្រា ១០.-

ក្រោយពីបានទទួលសេចក្តីជូនដំណឹងស្តីពីការសម្រេចយល់ព្រម ពីរាជរដ្ឋាភិបាល ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ត្រូវចេញលិខិតបញ្ជាក់ស្តីពីការសុំកូនចិញ្ចឹម ជូនសាមីអ្នកស្នើសុំកូនចិញ្ចឹម ។

ការប្រគល់ទារកកំព្រា ឬកុមារកំព្រាជូនឪពុក និងឬ ម្តាយចិញ្ចឹម ត្រូវធ្វើជាផ្លូវការនៅចំពោះមុខមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ជាអ្នកសម្របសម្រួល ។ ឪពុក និងឬ ម្តាយចិញ្ចឹម ត្រូវមានវត្តមាន ទទួលកូនដោយផ្ទាល់ក្នុងពេលនោះ ។ មិនអនុញ្ញាតឱ្យប្រគល់ទារកកំព្រា ឬកុមារកំព្រា តាមរយៈភ្នាក់ងារកណ្តាលណាមួយឡើយ ។

មាត្រា ១១.-

ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ត្រូវតាមដានពត៌មានជុំវិញការកូនចិញ្ចឹមសញ្ជាតិដើមកម្ពុជា រហូតដល់កុមារកំព្រារូបនោះ មានអាយុ ១៨ ឆ្នាំ ។

## ជំពូកទី ៣

## ករណីយកិច្ចរបស់សាមីអ្នកស្នើសុំកូន

មាត្រា ១២.-

សាមីអ្នកស្នើសុំកូនចិញ្ចឹមទាំងអស់ ត្រូវមានបន្ទុកដូចតទៅ :

- ធ្វើលិខិតធានាថែរក្សាទារកកំព្រា ឬកុមារកំព្រា ដែលសាមីខ្លួនបានស្នើសុំ
- រាយការណ៍ពីការលូតលាស់ [illegible] របស់ទារកកំព្រា ឬកុមារកំព្រា ។

មាត្រា ១៣.-

សាមីអ្នកស្នើសុំកូនអាចរួមធ្វើវិភាគទានមនុស្សធម៌ តាមការស្ម័គ្រចិត្ត ដល់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា [illegible] កុមារកំព្រា [illegible] ។

**មាត្រា ១៤.-**

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា មានភារកិច្ចគ្រប់គ្រង ប្រើប្រាស់ថវិកា វិភាគទានសប្បុរសធម៌នេះ តាមបទប្បញ្ញត្តិជាធរមាន និងដោយតម្លាភាព ។

## ជំពូកទី ៤

## អវសានប្បញ្ញត្តិ

**មាត្រា ១៥.-**

បទប្បញ្ញត្តិទាំងឡាយ ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនិតិសម្បទា និងរដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួង ស្ថាប័នពាក់ព័ន្ធ មានភារកិច្ចអនុវត្តអនុក្រឹត្យនេះ ដែលមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែ [illegible] ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

បានជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

**កន្លែងទទួល :**

- ខុទ្ទកាល័យព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ក្រសួងព្រះបរមរាជវាំង
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- គ្រប់ក្រសួង-ស្ថាប័ន
- គ្រប់សាលាខេត្ត-ក្រុង
- ដូចមាត្រា ១៦
- ឯកសារ-កាលប្បវត្តិ

KINGDOM OF CAMBODIA

NATION - RELIGION - KING

Ministry of Foreign Affairs
and International Cooperation

N° 524 MFA-IC/LC2

The Ministry of Foreign Affairs and International Cooperation presents its compliments to all Diplomatic and Consular Missions accredited to the Kingdom of Cambodia and has the honour to inform of the new procedure for the adoption of Cambodian orphans as follows:

1. Adoptive parents shall satisfy the following conditions:
- Shall be at the age of 25-55 years old for a married couple,
- Shall be at the age of 40-50 years old for a single parent,
- Have no children or have but not exceeding more than two children.
- Only two children are allowed to adopt,
- Adoptive parents shall submit 5 original application forms for the adoption of Cambodian orphan to the Ministry of Foreign Affairs and International Cooperation through their respective Diplomatic and Consular Missions.

2. An application form includes:
- Approval letter for the adoption of the competent authority of the adoptive parents' country,
- Home study made by the competent authority recognised by the government,
- Copy of Birth Certificate or a Certificate of Birth,
- Copy of Marriage Certificate or Divorce certificate or Certificate of Celibacy,
- Medical certificate,
- Psychological report issued by the psychiatrist recognised by the government of the adoptive parents,
- Certificate of no-criminal record issued by the competent authority,
- Certificate of behavior in the working place and society issued by the competent authority,
- Financial and property certificate issued by the competent authority,
- Promise letter to respect the rights of the adopted child and to provide education as well as the rights to obtain heritage as their own.

Address: N°. 161, Preah Sisowath Quay,
Phnom Penh, Kingdom of Cambodia

Tel: (855) 23 216 141
Fax:(855) 23 216 144 - 939
Email: mfaicasean@bigpond.com.kh

- Photos of the adoptive parents within the last two months,
- Promise letter of the adoptive parents to keep informed of bringing up the adopted child.
- Copy of passports of the adoptive parents,
- Note of the respective Diplomatic or Consular Missions certifying that all documents concerned are authentic.

3. <u>A choosing adopted child</u>:
- Upon agreed on the request of the adoption by the Royal Government of Cambodia, the Ministry of Foreign Affairs and International Cooperation will inform the adoptive parents through their respective Diplomatic or Consular Missions to come and choose the child in the list of Orphans of the Ministry of Social Affairs, Labour, Vocational Training and Youth Rehabilitation,
- Adoptive parents are allowed to go and see the child in the orphanage before making a final decision to take a child.

4. <u>Handing over the child</u>:
- Upon agreed on the request of adoption by the Royal Government of Cambodia the Ministry of Social Affairs, Labour, Vocational Training and Youth Rehabilitation will issue a certificate of adoption to the adoptive parents.
- Adoptive mother and/or adoptive father shall come to take the child themselves in the presence of the officials of the Ministry of Social Affairs, Labour, Vocational Training and Youth Rehabilitation,
- Handing over the child through third person is not permitted.

5. <u>Report on bringing up the child</u>:
- Adoptive parents shall send every year a report on bringing up the child, which certified by the competent authority, from the time he or she was taken out from Cambodia until he or she reaches the age of 18 years old, to the Ministry of Social Affairs, Labour, Vocational Training and Youth Rehabilitation. This report shall also be copied to the Royal Embassy of Cambodia accredited in that country.

6. <u>Expense of the adoptive parents</u>:
- Adoptive parents shall take responsibility for the following:
  . Passport for the adopted child,
  . All expanses for the adopted child to leave the country.

- The adoptive parents are required to give voluntarily donation for the humanitarian purpose to the Ministry of Social Affairs, Labour, Vocational Training and Youth Rehabilitation for the sake of all Cambodian orphans within the country.

The Ministry of Foreign Affairs and International Cooperation avails itself of this opportunity to renew to all Diplomatic and Consular Missions accredited to the Kingdom of Cambodia the assurances of its highest consideration.

Phnom Penh, [illegible] March 2001

ALL DIPLOMATIC AND
CONSULAR MISSIONS ACCREDITED
TO THE KINGDOM OF CAMBODIA.